




វត្ថុបំណង

រៀនឲ្យដឹងថា

តើដំណឹងល្អដែលនាំការសង្គ្រោះមានលក្ខណៈយ៉ាងណា

តើអ្នកអាចទទួលការសង្គ្រោះដោយរបៀបណា

ដើម្បីឲ្យអ្នកបានទទួលការសង្គ្រោះនិងនាំមនុស្សដទៃទៀតមកទទួលការសង្គ្រោះ

តាមរយៈការកែប្រែចិត្តគំនិតនិងការជឿលើដំណឹងល្អ។

១.ការបិទបាំងពីរប្រភេទ
លោកុប្បត្តិ ៣:៧,២១
៧ ពេលនោះ ស្រាប់តែភ្នែករបស់អ្នកទាំងពីរបានភ្លឺឡើង
ហើយដឹងថាគេនៅខ្លួនទទេ។
អ្នកទាំងពីរក៏បេះ ស្លឹកល្វា មកខ្ទាស់ធ្វើជាប៉ឹងបិទបាំងកាយ។
២១ ព្រះជាអម្ចាស់បានយក ស្បែកសត្វ មកធ្វើជាសម្លៀកបំពាក់
ឲ្យលោកអដាំនិងភរិយារបស់គាត់។

មានការបិទបាំង(ការបំបាត់ភាពអាម៉ាស់និងការផ្តល់តម្លៃ)ពីរប្រភេទគឺៈ
- ការបិទបាំងដោយស្លឹកល្វា(ការប្រឹងប្រែងរបស់មនុស្ស)
- ការបិទបាំងដោយស្បែកសត្វ(អំណោយរបស់ព្រះជាម្ចាស់)។

ផែនការប្រោសមនុស្សលោកឲ្យបានសុចរិតតាមរយៈព្រះយេស៊ូ
២កូរិនថូស ៥:២១
២១ ព្រះគ្រិស្តគ្មានបាបទាល់តែសោះ
តែព្រះជាម្ចាស់បានធ្វើឲ្យព្រះអង្គទៅជាតួបាបសម្រាប់យើង
ដើម្បីប្រោសយើងឲ្យ បានសុចរិត រួមជាមួយព្រះគ្រិស្តដែរ។

ផែនការសង្គ្រោះមនុស្សលោកតាមរយៈព្រះយេស៊ូ
យ៉ូហាន ៣:១៦
១៦ ព្រះជាម្ចាស់ស្រឡាញ់មនុស្សលោកខ្លាំងណាស់
ហេតុនេះហើយបានជាព្រះអង្គប្រទានព្រះបុត្រាតែមួយរបស់ព្រះអង្គមក
ដើម្បីឲ្យអស់អ្នកដែលជឿលើព្រះបុត្រា
មាន ជីវិតអស់កល្បជានិច្ច គឺមិនឲ្យគេវិនាសឡើយ។

ក្រោយពីលោកអដាំនិងនាងអេ៉វ៉ាបានធ្វើបាប
ដោយបរិភោគផ្លែឈើដែលព្រះជាម្ចាស់ហាមឃាត់
ព្រះអង្គមិនបានបោះបង់ពួកគាត់ចោលឡើយ។
ដោយសារព្រះជាម្ចាស់ស្រឡាញ់ពួកគាត់ឥតប្រែប្រួល
ព្រះអង្គបានសម្លាប់សត្វចៀមដើម្បីយកស្បែកវា
មកធ្វើជាសម្លៀកបំពាក់សម្រាប់បិទបាំងពួកគាត់។
សត្វចៀមតំណាងឲ្យព្រះយេស៊ូជាបុត្រារបស់ព្រះជាម្ចាស់
ដែលព្រះជាម្ចាស់មានផែនការបាត់ព្រះអង្គឲ្យយាងមកផែនដីនេះ
មកសោយទិវង្គតនៅលើឈើឆ្កាងដើម្បីដោះបាបមនុស្សលោក
និងដើម្បីប្រោសមនុស្សលោកឲ្យបានសុចរិត។
«កូនចៀម»ជានាមមួយទៀតរបស់ព្រះយេស៊ូ(វិវរណៈ ៥:៨,១២,១៣)។



ការបិទបាំងដោយស្លឹកល្វាតំណាងឲ្យ«សាសនាក្រឹត្យវិន័យ»
ដែលបំបាត់ភាពអាម៉ាស់និងផ្តល់តម្លៃដល់មនុស្សតាមរយៈការប្រព្រឹត្តល្អរបស់ខ្លួនឯង។
ស្លឹកឈើ(សេចក្តីសុចរិតរបស់មនុស្ស)ឆាប់ក្រៀមស្រពោនហើយមិនគង់វង្សបានយូរទេ។



ការបិទបាំងដោយស្បែកសត្វតំណាងឲ្យ«សាសនាព្រះគុណ»
ដែលបំបាត់ភាពអាម៉ាស់និងផ្តល់តម្លៃដល់មនុស្សតាមរយៈអំណោយរបស់ព្រះជាម្ចាស់។
ស្បែកសត្វ(សេចក្ដីសុចរិតរបស់ព្រះជាម្ចាស)មិនងាយសឹករេចរិលទេហើយគង់វង្សបានយូរ។

២.ការថ្វាយបង្គំពីរប្រភេទ
លោកុប្បត្តិ ៤:៣-៥
៣ លុះដល់ពេលប្រមូលផលហើយ
លោកកាអ៊ីនក៏យក <u>ភោគផលពីស្រែចំការរបស់គាត់</u> មកថ្វាយព្រះអម្ចាស់។
៤ លោកអេបិលក៏បាននាំយក <u>កូនសត្វ</u> ដែលកើតមុនគេបង្អស់
ក្នុងហ្វូងសត្វរបស់គាត់ព្រមទាំងខ្លាញ់របស់វាមកថ្វាយដែរ។
ព្រះអម្ចាស់គាប់ព្រះហឫទ័យនឹងលោកអេបិលព្រមទាំងតង្វាយរបស់គាត់
៥ តែព្រះអង្គមិនគាប់ព្រះហឫទ័យនឹងលោកកាអ៊ីនព្រមទាំងតង្វាយរបស់គាត់ទេ។

មានការថ្វាយបង្គំ(នមស្ការ ការគោរពបូជា ការថ្វាយគ្រឿងបូជា)ពីរប្រភេទគឺ៖
- ការថ្វាយបង្គំដោយពឹងការប្រព្រឹត្ត(ពឹងលើផលនៃកម្លាំងរបស់ខ្លួនឯង)
- ការថ្វាយបង្គំដោយពឹងលើជំនឿ(ពឹងលើកូនចៀមជាយញ្ញបូជារំដោះបាប)។

ព្រះជាម្ចាស់គាប់ព្រះហឫទ័យនឹងលោកអេបិលព្រមទាំងការថ្វាយបង្គំដោយជំនឿ។

ព្រះយេស៊ូជាកូនចៀមរបស់ព្រះជាម្ចាស់
យ៉ូហាន ១:២៩-៣០,៣៤
២៩ នៅថ្ងៃបន្ទាប់ លោកយ៉ូហានឃើញព្រះយេស៊ូយាងតម្រង់មករកលោក
រួចលោកក៏មានប្រសាសន៍ថា៖
«មើលហ្ន៎! លោកនេះហើយជា កូនចៀម របស់ព្រះជាម្ចាស់
ដែលដកបាបចេញពីមនុស្សលោក
៣០ គឺលោកនេះហើយដែលខ្ញុំបានប្រាប់អ្នករាល់គ្នាថា
"អ្នកដែលមកក្រោយខ្ញុំប្រសើរជាងខ្ញុំដ្បិតលោកមានជីវិតមុនខ្ញុំ"។
៣៤ ខ្ញុំបានឃើញដូច្នោះមែន
ហើយខ្ញុំសូមបញ្ជាក់ថាលោកនេះពិតជាព្រះបុត្រារបស់ព្រះជាម្ចាស់មែន។

កូនចៀមរបស់ព្រះជាម្ចាស់គឺកូនចៀមយញ្ញបូជាដែលពលីជីវិតដើម្បីដោះបាបមនុស្សលោក។

លោកអេបិលមិនថ្វាយអំពើល្អរបស់គាត់(ផលល្អនៃកម្លាំងរបស់គាត់)
ជាគ្រឿងបូជាដល់ព្រះជាម្ចាស់ទេ ព្រោះគ្រឿងបូជាប្រភេទនេះ
មិននាំឲ្យគាត់បានសុចរិតដល់កម្រិតដែលព្រះជាម្ចាស់គាប់ព្រះហឫទ័យបានឡើយ។
លោកអេបិលថ្វាយគ្រឿងបូជាមួយដែលព្រះជាម្ចាស់គាប់ព្រះហឫទ័យ
គឺកូនចៀមមួយដែលជានិមិត្តរូបរបស់ព្រះយេស៊ូ
ជា«កូនចៀមយញ្ញបូជារបស់យើង»(២កូរិនថូស ៥:៧)។
គាត់មានជំនឿថាព្រះយេស៊ូគ្រិស្តជាកូនចៀមយញ្ញបូជាតែមួយគត់
ដែលនាំឲ្យគាត់បានសុចរិតដល់កម្រិតដែលព្រះជាម្ចាស់គាប់ព្រះហឫទ័យ។
«ព្រះជាម្ចាស់ប្រោសអ្នកដែលមានជំនឿលើព្រះយេស៊ូគ្រិស្តឲ្យបានសុចរិត
គឺព្រះអង្គធ្វើដូច្នេះចំពោះអស់អ្នកដែលជឿ»។(រ៉ូម៨:២២)



នៅលើលោកនេះមានសាសនាច្រើនណាស់ ប៉ុន្តែមានការថ្វាយបង្គំតែពីរប្រភេទប៉ុណ្ណោះ
គឺការថ្វាយបង្គំដោយពឹងលើផលនៃកម្លាំងរបស់ខ្លួនឯងផ្ទាល់( ពឹងលើការប្រព្រឹត្ត)
និងការថ្វាយបង្គំដោយពឹងលើព្រះយេស៊ូគ្រិស្តជាយញ្ញបូជារំដោះបាប( ពឹងលើជំនឿ )។

៣.ទ្វារពីរប្រភេទ
ម៉ាថាយ ៧:១៣-១៤
១៣ ចូរនាំគ្នាចូលតាមទ្វារចង្អៀត
ដ្បិតទ្វារដែលនាំទៅរក សេចក្តីវិនាសអន្តរាយ ធំណាស់
ហើយផ្លូវទៅរកសេចក្តីវិនាសក៏ទូលាយដែរ មានមនុស្សជាច្រើនចូលតាមទ្វារនោះ។
១៤ រីឯទ្វារដែលនាំទៅរក ជីវិត ចង្អៀតហើយពិបាកដើរផង
មានមនុស្សតិចទេរកផ្លូវនោះឃើញ»។

មានទ្វារ( ប្រក ផ្លូវ )ពីរប្រភេទគឺ៖
- ទ្វារដែលនាំទៅរកសេចក្តីវិនាសអន្តរាយ( ធំទូលាយ មនុស្សជាច្រើនចូលតាមទ្វារនេះ )
- ទ្វារដែលនាំទៅរកជីវិត( តូចចង្អៀតហើយពិបាកចូល មនុស្សតិចទេរកផ្លូវនេះឃើញ )។



ទ្វារ( ប្រក ផ្លូវ )ដែលនាំទៅរកសេចក្តីវិនាសអន្តរាយធំទូលាយហើយស្រួលចូល។
ដោយសារមនុស្សកសាងទ្វារនេះឡើងដោយខ្លួនឯង មនុស្សអាចពង្រីកវាបានតាមចិត្ត
ដោយបន្ថែមទំហំនិងគ្រឿងលម្អផ្សេងៗលើវាតាមរសនិយមនិងតាមលទ្ធភាពរបស់ខ្លួន។



ទ្វារ( ប្រក ផ្លូវ )ដែលនាំទៅរកជីវិតពេញបរិបូណ៌តូចចង្អៀតហើយពិបាកចូល។
ដោយសារទ្វារនេះជាអំណោយមកពីព្រះជាម្ចាស់ មនុស្សមិនអាចពង្រីកវាតាមចិត្តរបស់ខ្លួន
ដោយបន្ថែមទំហំនិងគ្រឿងលម្អផ្សេងៗលើវាតាមរសនិយមនិងតាមលទ្ធភាពរបស់ខ្លួនទេ។

៤.មនុស្សពីរប្រភេទ
សុភាសិត ១១:២៨
២៨ មនុស្សដែលពឹងផ្អែកលើ ទ្រព្យសម្បត្តិ មុខជាត្រូវអន្តរាយ
រីឯ មនុស្សសុចរិត ប្រៀបបាននឹងស្លឹកឈើដែលលាស់ខៀវខ្ចី។





មានមនុស្សពីរប្រភេទគឺ៖

- មនុស្សដែលពឹងផ្អែកលើទ្រព្យសម្បត្តិ(មនុស្សទុច្ចរិត)
- មនុស្សដែលពឹងផ្អែកលើព្រះជាម្ចាស់(មនុស្សសុចរិត)។

ក.មនុស្សដែលពឹងផ្អែកលើទ្រព្យសម្បត្តិ
យេរេមា ១៧:៥
៥ ព្រះអម្ចាស់មានព្រះបន្ទូលទៀតថាជនណាដែលផ្ញើជីវិតលើមនុស្ស
ហើយទុកចិត្តលើអ្វីៗដែលជាលោកីយ៍ដោយបែរចិត្តចេញពីព្រះអម្ចាស់
ជននោះមុខជា ត្រូវបណ្តាសា ពុំខាន!



លក្ខណៈសម្គាល់របស់មនុស្សដែលពឹងផ្អែកលើទ្រព្យសម្បត្តិ

- ចូលចិត្តផ្ញើជីវិតលើមនុស្ស
- ទុកចិត្តលើអ្វីៗដែលជាលោកីយ៍
- បែរចិត្តចេញពីព្រះអម្ចាស់



មនុស្សដែលពឹងផ្អែកលើទ្រព្យសម្បត្តិមុខជាត្រូវបណ្ដាសាពុំខាន។

យេរេមា ១៧:៦

៦ គេប្រៀបបាននឹងដើមឈើក្រិននៅតាមព្រៃល្បោះ
គេពុំអាចជួបនឹងសុភមង្គលឡើយ។
គេរស់នៅតាមកន្លែងក្ដៅហួតហែង
ក្នុងវាលរហោស្ថានជាដីដែលគ្មានអ្វីដុះនិងគ្មានមនុស្សនៅ។



## វាសនារបស់មនុស្សដែលពឹងផ្អែកលើទ្រព្យសម្បត្តិ

មនុស្សដែលពឹងផ្អែកលើទ្រព្យសម្បត្តិមានវាសនាដូចតទៅៈ

- គេប្រៀបបាននឹងដើមឈើក្រិន
- គេគ្មានសុភមង្គលឡើយ
- គេមានភាពក្តៅក្រហាយ
- គេមានភាពឯកោ
- គេមានភាពក្រៀមក្រោះ
- គេគ្មានផ្លែផ្កាអ្វីឡើយ។



ទីបន្ទាល់: អ្នកមាននិងអ្នកចេះដឹងដែលរងទុក្ខវេទនានៅសម័យលានពិឃាត។

## ខ.មនុស្សដែលពឹងផ្អែកលើព្រះជាម្ចាស់

យេរេមា ១៧:៧

៧ រីឯអ្នកដែលផ្ញើជីវិតលើព្រះអម្ចាស់
និងយកព្រះអង្គធ្វើជាបង្អែក
ពិតជា ទទួលព្រះពរ មិនខាន!



## លក្ខណៈសម្គាល់របស់មនុស្សដែលពឹងផ្អែកលើព្រះជាម្ចាស់

មនុស្សដែលពឹងផ្អែកលើព្រះជាម្ចាស់មានលក្ខណៈសម្គាល់ដូចតទៅ៖

- យកព្រះជាម្ចាស់ធ្វើជាបង្អែក
- បានសុចរិតដោយសារជំនឿ
- បានសុចរិតដោយសារការប្រោសលោះរបស់ព្រះគ្រិស្ត ដែលសោយទិវង្គតលើឈើឆ្កាងដើម្បីបង់ថ្លៃលោះបាបគាត់ទាំងស្រុង
- បានទទួលសេចក្តីសុចរិតជាអំណោយមកពីព្រះជាម្ចាស់ គាត់មិនបាច់ធ្វើល្អដើម្បីដូរយកសេចក្តីសុចរិតទេ
- ទទួលព្រះពររួមជាមួយលោកអប្រាហាំតាមរយៈព្រះគ្រិស្ត។

មនុស្សដែលពឹងផ្អែកលើព្រះជាម្ចាស់មុខជាទទួលព្រះពរពុំខាន។

រ៉ូម ៣:២៤

២៤ តែដោយសារ ព្រះគុណ និងដោយសារ ការប្រោសលោះ ដែលស្ថិតនៅ ក្នុងអង្គព្រះគ្រិស្តយេស៊ូ ព្រះអម្ចាស់ ប្រោសគេឲ្យបានសុចរិត ដោយឥតគិតថ្លៃ។



ព្រះគុណជួយយើងឲ្យបានទទួលអ្វីៗដែលយើងមិនសក្តិសមនឹងទទួល។

យេរេមា ១៧:៨

៨ អ្នកនោះ
ប្រៀបបាននឹង ដើមឈើ
ដុះនៅក្បែរផ្លូវទឹក
ដែលមានឫសចាក់ទៅរកទឹកហូរ
វាមិនខ្លាចកំដៅ
ហើយស្លឹករបស់វានៅខៀវខ្ចីជានិច្ច។
នៅពេលរាំងស្ងួត
វាមិនព្រួយបារម្ភអ្វីទេ
គឺវានៅតែបង្កើតផ្លែផ្កាដដែល។



ព្រះបន្ទូលនេះបង្រៀនយើងយ៉ាងច្បាស់អំពីវាសនារបស់មនុស្សសុចរិត។

វាសនារបស់មនុស្សដែលពឹងផ្អែកលើព្រះជាម្ចាស់

មនុស្សដែលពឹងផ្អែកលើព្រះជាម្ចាស់មានវាសនាដូចតទៅ៖

- គេប្រៀបបាននឹងដើមឈើដុះក្បែរផ្លូវទឹកដែលចាក់ឫសដល់ប្រភពទឹក
- គេនៅតែមានភាពស្រស់បំព្រងនៅពេលហួតហែង
- គេនៅតែអាចបង្កើតផលបាននៅពេលខ្វះខាត។



សូមធ្វើបន្ទាល់អំពីវាសនារបស់អ្នកក្រោយពីអ្នកបានពឹងផ្អែកលើព្រះជាម្ចាស់។

៥.អ្នកមិនជឿប្រាំពីរប្រភេទ

តើកន្លងមកអ្នកស្ថិតនៅក្នុងចំណោមអ្នកមិនជឿប្រភេទមួយណា?

- មនុស្សដែលអាងអំពើល្អ(ម៉ាថាយ ១៩:១៦,២០)
- មនុស្សដែលអាងតម្រិះប្រាជ្ញា(រ៉ូម ១:២១-២៣)
- មនុស្សដែលអាងទ្រព្យសម្បត្តិ(លូកា ១២:១៦-២១)
- មនុស្សដែលសាហាវយង់ឃ្នង(រ៉ូម ៣:១៣-១៨)
- មនុស្សដែលមើលឃើញខ្លួនឯងមិនសក្តិសម(យ៉ូហាន ៤:៩)
- មនុស្សក្រីក្រ ជាប់ចំណង ខ្វាក់ និងត្រូវគេជិះជាន់(លូកា ៤:១៨)
- មនុស្សដែលស្វែងរកសេចក្តីពិត(យ៉ូហាន ៣:២,៤)។

ព្រះយេស៊ូស្រឡាញ់ ស្វែងរក និងសង្គ្រោះអ្នកមិនជឿគ្រប់ប្រភេទ។

៦.ព្រះយេស៊ូយាងមកដើម្បីសង្គ្រោះមនុស្សលោក

យ៉ូហាន ៣:១៧-១៨

១៧ ព្រះជាម្ចាស់បានចាត់ព្រះបុត្រារបស់ព្រះអង្គឲ្យយាងមកក្នុងលោកនេះ
ពុំមែនដើម្បីដាក់ទោសមនុស្សលោកទេ
គឺដើម្បី សង្គ្រោះ មនុស្សលោកដោយសារព្រះបុត្រាវិញ។
១៨ អ្នកជឿលើព្រះបុត្រាមិនត្រូវទទួលទោសទេ
រីឯអ្នកមិនជឿបានទទួលទោសរួចស្រេចទៅហើយ
ព្រោះគេពុំបានជឿលើព្រះនាមព្រះបុត្រាតែមួយរបស់ព្រះជាម្ចាស់។

តើមនុស្សលើលោកនេះឆ្លើយតបយ៉ាងណាចំពោះការសង្គ្រោះរបស់ព្រះយេស៊ូ?

- អ្នកខ្លះព្រមជឿព្រះយេស៊ូ(មិនត្រូវទទួលទោសទេ)
- អ្នកខ្លះមិនព្រមជឿព្រះអង្គទេ(ទទួលទោសរួចហើយ)។

## ៧.ដំណឹងល្អដែលនាំការសង្គ្រោះ

១កូរិនថូស ១៥:១-២

១ បងប្អូនអើយ ខ្ញុំសូមរំលឹកបងប្អូន ដំណឹងល្អដែលខ្ញុំបានប្រកាសប្រាប់បងប្អូន
ជាដំណឹងល្អដែលបងប្អូនបានទទួលនិងបានជឿយ៉ាងខ្ជាប់ខ្ជួនស្រាប់ហើយ។
២ ប្រសិនបើបងប្អូនមិនឃ្លាតចាកពីដំណឹងល្អ
ដែលខ្ញុំបានប្រកាសប្រាប់បងប្អូនទេនោះ
បងប្អូននឹងទទួលការសង្គ្រោះតាមរយៈ ដំណឹងល្អនេះ ដែរ។
បើឃ្លាតចាក ជំនឿរបស់បងប្អូនមុខតែឥតប្រយោជន៍។

- ដំណឹងល្អពិតប្រាកដនាំឲ្យមនុស្សបានទទួលការសង្គ្រោះ
- ដំណឹងល្អក្លែងក្លាយនាំឲ្យជំនឿរបស់គេទៅជាឥតប្រយោជន៍។

## ខ្លឹមសារទាំងបីនៃដំណឹងល្អ

១កូរិនថូស ១៥:៣-៤

៣ មុនដំបូងបង្អស់ ខ្ញុំជំរាបជូនបងប្អូននូវសេចក្តីដែលខ្ញុំបានទទួល
គឺថាព្រះគ្រិស្តបានសោយទិវង្គតដើម្បីរំដោះបាបយើងស្របតាមគម្ពីរ។
៤ គេបានបញ្ចុះព្រះសពព្រះអង្គនៅក្នុងផ្នូរ
ហើយព្រះអង្គមានព្រះជន្មរស់ឡើងវិញនៅថ្ងៃទីបីស្របតាមគម្ពីរ។







ដំណឹងល្អ

- ព្រះគ្រិស្តបានសោយទិវង្គតដើម្បីរំដោះបាបយើងស្របតាមគម្ពីរ
- គេបានបញ្ចុះព្រះសពព្រះអង្គនៅក្នុងផ្នូរ
- ហើយព្រះអង្គមានព្រះជន្មរស់ឡើងវិញនៅថ្ងៃទីបីស្របតាមគម្ពីរ។

ដោយសារខ្ញុំជឿលើដំណឹងល្អរបស់ព្រះគ្រិស្ត
ជីវិតចាស់របស់ខ្ញុំ( ចរិត និស្ស័យ ព្រលឹង )បានជាប់ឆ្កាងរួមជាមួយព្រះគ្រិស្តហើយ
ជីវិតចាស់របស់ខ្ញុំ( ចរិត និស្ស័យ ព្រលឹង )បានបញ្ចុះក្នុងផ្នូររួមជាមួយព្រះគ្រិស្តហើយ
ជីវិតថ្មីរបស់ខ្ញុំ( ព្រលឹងនិងវិញ្ញាណ )បានរស់ឡើងវិញរួមជាមួយព្រះគ្រិស្តហើយ។
ដោយសារខ្ញុំជឿលើដំណឹងល្អរបស់ព្រះយេស៊ូគ្រិស្ត
ខ្ញុំបានទទួលការសង្គ្រោះនិងមានជីវិតអស់កល្បជានិច្ច។

## ៨.ជីវិតអស់កល្បជានិច្ច

យ៉ូហាន ១៧:៣
៣ រីឯ
<u>ជីវិតអស់កល្បជានិច្ច</u> នោះ
គឺឲ្យគេស្គាល់ព្រះអង្គ
ដែលជាព្រះជាម្ចាស់
ដ៏ពិតតែមួយគត់
និងឲ្យគេស្គាល់
ព្រះយេស៊ូគ្រិស្ត
ដែលព្រះអង្គចាត់ឲ្យមក។



ជីវិតអស់កល្បជានិច្ចបានមកពីការស្គាល់ព្រះជាម្ចាស់និងការស្គាល់ព្រះយេស៊ូគ្រិស្ត
ជាព្រះបុត្រាដែលព្រះជាម្ចាស់ចាត់ឲ្យមកសង្គ្រោះមនុស្សលោកនៅលើផែនដីនេះ។

ជីវិតអស់កល្បជានិច្ច
គឺការស្គាល់ព្រះបិតាថាជាព្រះជាម្ចាស់ដ៏ពិតតែមួយគត់
និងការស្គាល់ព្រះយេស៊ូគ្រិស្តថាជាព្រះបុត្រាដែលព្រះជាម្ចាស់ចាត់ឲ្យមក។

ស្គាល់ព្រះបិតាថាជាព្រះជាម្ចាស់ដ៏ពិតតែមួយគត់
គឺដឹងថាព្រះអង្គគង់នៅអស់កល្បជានិច្ច ព្រះអង្គគង់នៅគ្រប់ទីកន្លែង
ព្រះអង្គជ្រាបដឹងទាំងអស់ ព្រះអង្គមានឫទ្ធានុភាពគ្រប់យ៉ាង
ព្រះអង្គស្រឡាញ់មនុស្សលោកខ្លាំងណាស់
ហើយព្រះអង្គសង្គ្រោះមនុស្សលោកតាមរយៈព្រះបុត្រារបស់ព្រះអង្គ។

ស្គាល់ព្រះយេស៊ូគ្រិស្តថាជាព្រះបុត្រាដែលព្រះជាម្ចាស់ចាត់ឲ្យមក
គឺស្គាល់ព្រះយេស៊ូថាជាព្រះបុត្រាដែលព្រះជាម្ចាស់ចាត់ឲ្យមកនិងចាក់ប្រេងអភិសេក
ជាព្រះគ្រិស្ត( ព្យាការី ក្សត្រ និងបូជាចារ្យ )ដើម្បីសង្គ្រោះមនុស្សលោកលើផែនដីនេះ។

យើងមានជីវិតអស់កល្បជានិច្ចដោយសារជំនឿ
យ៉ូហាន ៣:១៤-១៦
១៤ កាលនៅវាលរហោស្ថាន លោកម៉ូសេបានលើកពស់ឡើងយ៉ាងណា
បុត្រមនុស្សនឹងត្រូវគេលើកឡើងយ៉ាងនោះដែរ
១៥ ដើម្បីឲ្យអស់អ្នកដែលជឿលើព្រះអង្គមាន ជីវិតអស់កល្បជានិច្ច។
១៦ ព្រះជាម្ចាស់ស្រឡាញ់មនុស្សលោកខ្លាំងណាស់
ហេតុនេះហើយបានជាព្រះអង្គប្រទានព្រះបុត្រាតែមួយរបស់ព្រះអង្គមក
ដើម្បីឲ្យអស់អ្នកដែលជឿលើព្រះបុត្រាមាន ជីវិតអស់កល្បជានិច្ច គឺមិនឲ្យគេវិនាសឡើយ។

ជីវិតអស់កល្បជានិច្ចបានមកពីការជឿលើព្រះយេស៊ូ
ថាជាព្រះបុត្រាដែលព្រះជាម្ចាស់ចាត់ឲ្យមកនិងចាក់ប្រេងអភិសេក
ជាព្រះគ្រិស្ត( ព្យាការី ក្សត្រ និងបូជាចារ្យ )ដើម្បីសង្គ្រោះមនុស្សលោកលើផែនដីនេះ។

## ៩.របៀបទទួលការសង្គ្រោះ

ម៉ាកុស ១:១៥

១៥ ព្រះអង្គមានព្រះបន្ទូលថា៖
«ពេលកំណត់មកដល់ហើយ
រីឯព្រះរាជ្យរបស់ព្រះជាម្ចាស់ក៏មកជិតបង្កើយដែរ។
ចូរនាំគ្នា កែប្រែចិត្តគំនិត ហើយ ជឿ ដំណឹងល្អចុះ!»។

តើមនុស្សអាចទទួលការសង្គ្រោះបានដោយរបៀបណា?
មនុស្សអាចទទួលការសង្គ្រោះបានដោយធ្វើកិច្ចការពីរយ៉ាងគឺ៖

- ការកែប្រែចិត្តគំនិត
- ការជឿលើដំណឹងល្អ។

## កែប្រែចិត្តគំនិត

គឺបែរចេញពីការពឹងលើ ខ្លួនឯង និង ព្រះក្លែងក្លាយ មកពឹងលើព្រះយេស៊ូវិញ។

## ជឿលើដំណឹងល្អ

គឺជឿថាព្រះយេស៊ូបានសោយទិវង្គតលើឈើឆ្កាងដើម្បីរំដោះបាបយើង
ព្រះអង្គត្រូវគេបញ្ចុះក្នុងផ្នូរដើម្បីបញ្ចុះជីវិតចាស់របស់យើងរួមជាមួយព្រះអង្គ
ហើយនៅថ្ងៃទីបីព្រះអង្គមានព្រះជន្មរស់ឡើងវិញដើម្បីប្រោសយើងឲ្យសុចរិត។







១០.ទស្សនៈផ្សេងៗអំពីការសង្គ្រោះ

តើទស្សនៈមួយណាអំពីការសង្គ្រោះដែលអ្នកយល់ឃើញថាត្រឹមត្រូវ?

ក.ខំតែធ្វើល្អទៅគ្រប់គ្រាន់ហើយមិនបាច់កាន់សាសនាណាទាំងអស់

ខ.សាសនាទាំងអស់សុទ្ធតែមានបំណងឲ្យមនុស្សបានសង្គ្រោះដូចគ្នា

គ.ឲ្យតែកាន់សាសនាណាមួយបានល្អនោះនឹងបានសង្គ្រោះហើយ

ឃ.កុំកាន់សាសនាតែមួយ ត្រូវកាន់សាសនាឲ្យបានច្រើនទើបបានសង្គ្រោះ

ង.មានតែគ្រិស្តសាសនាមួយគត់ដែលជួយមនុស្សឲ្យបានសង្គ្រោះ

ច.ឲ្យតែគោរពវិញ្ញាណក្ខន្ធបុព្វការីបានល្អនោះយើងនឹងបានសង្គ្រោះ

ឆ.ជឿលើព្រះនាមព្រះយេស៊ូតែមួយអង្គគត់នោះយើងនឹងបានសង្គ្រោះ។

ទស្សនៈអំពីការសង្គ្រោះដែលត្រឹមត្រូវគឺទស្សនៈ“ឆ”។

សំណួរបញ្ជាក់ការអនុវត្ត

1. កាលពីមុនតើអ្នកជាមនុស្សប្រភេទណា?
   ជាមនុស្សដែលពឹងផ្អែកលើទ្រព្យសម្បត្តិឬពឹងផ្អែកលើព្រះជាម្ចាស់?
2. ឥឡូវនេះតើអ្នកជាមនុស្សប្រភេទណា?
   ជាមនុស្សដែលពឹងផ្អែកលើទ្រព្យសម្បត្តិឬពឹងផ្អែកលើព្រះជាម្ចាស់?
3. តើដំណឹងល្អគឺជាអ្វី? តើជីវិតអស់កល្បជានិច្ចគឺជាអ្វី?
4. តើអ្នកអាចទទួលការសង្គ្រោះបានដោយរបៀបណា?
5. តើអ្នកកែប្រែចិត្តគំនិតដោយរបៀបណា?
6. តើអ្នកជឿលើដំណឹងល្អដោយរបៀបណា?
7. តើអ្នកមានផែនការបែបណាដើម្បីនាំការសង្គ្រោះដល់ញាតិមិត្តអ្នក?
8. សូមទន្ទេញនិងសញ្ជឹងគិតបទគម្ពីរ ម៉ាកុស ១:១៥។